ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១២ អយក.សណន

## សេចក្ដីណែនាំ
## ស្ដីពី
## ការពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងនៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ ដើម្បីលើកកម្ពស់ចរិយាសម្បទារបស់សិស្ស

អនុលោមតាមច្បាប់ស្ដីពីការអប់រំ ដែលបានកំណត់អំពីសិទ្ធិ ករណីយកិច្ចរបស់អ្នកសិក្សា មាតាបិតា ឬ អ្នកអាណាព្យាបាល និងសិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលិកអប់រំ និងអនុលោមតាមកម្មវិធីសិក្សាព្រមទាំងសេចក្ដីណែនាំស្ដីពី ដំណើរការគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ គ្រឹះស្ថានសិក្សាទាំងអស់ត្រូវយកចិត្តទុកដាក់ទៅលើការអប់រំ ដើម្បីសម្រេចបាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា តាមរយៈការអនុវត្តកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា។ ការអប់រំចរិយាសម្បទារបស់អ្នកសិក្សា គឺជា ភារកិច្ច និងទាមទារការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់ រួមមាន៖ គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន មាតាបិតា អ្នកអាណាព្យាបាល និងអាជ្ញាធរពាក់ព័ន្ធ ក៏ដូចជាសង្គមជាតិទាំងមូល។

ដើម្បីបន្តពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងនៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ និងលើកកម្ពស់ចរិយាសម្បទារបស់សិស្ស ក្រសួងអប់រំ យុវជន និងកីឡាសូមដាក់ចេញនូវសេចក្ដីណែនាំដូចខាងក្រោម៖

### ១. គ្រឹះស្ថានសិក្សា

- បង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងដំណើរការឱ្យមានប្រសិទ្ធភាព ដោយមានការចូលរួមពីមាតាបិតា ឬ អ្នកអាណាព្យាបាល
- ជួបប្រជុំ ពិភាក្សា និងទាក់ទងមាតាបិតា ឬ អ្នកអាណាព្យាបាលឱ្យបានទៀងទាត់ ដើម្បីពិភាក្សាលទ្ធផលសិក្សារបស់សិស្ស និងដោះស្រាយបញ្ហាដែលកើតមានឡើងជាយថាហេតុ
- ប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការគ្រប់គ្រងសាលារៀន ដើម្បីឱ្យមាតាបិតាមានលទ្ធភាពក្នុងការត្រួតពិនិត្យមើលវត្តមាន ពិន្ទុ និងវិន័យរបស់អ្នកសិក្សា
- បង្កើតក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជានៅក្នុងគ្រឹះស្ថានសិក្សា និងត្រូវចាត់តាំងនាយករងមួយរូបឱ្យទទួលបន្ទុកការងារក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា
- ពង្រឹងទំនាក់ទំនងរវាងក្រុមប្រឹក្សាកុមារកម្ពុជានិងក្រុមប្រឹក្សាយុវជនកម្ពុជាជាមួយគ្រូទទួលបន្ទុកថ្នាក់
- បង្កើតក្រុមប្រឹក្សាវិន័យ ដើម្បីផ្ដល់ការលើកទឹកចិត្ត ឬដាក់ទណ្ឌកម្មខាងវិន័យ ដល់អ្នកសិក្សាដែលអនុវត្តល្មើសបទបញ្ជាផ្ទៃក្នុង ឬប្រាសចាកពីសីលធម៌



អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
info@moeys.gov.kh / administration@moeys.gov.kh
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២២០ ៦៧៣ / ២២០ ៣០៤
www.moeys.gov.kh

- រាយការណ៍អំពីសកម្មភាពមិនប្រក្រតី ឬអំពើល្មើស ដែលបានកើតឡើងក្នុងគ្រឹះស្ថានសិក្សាឱ្យបានទាន់ពេលវេលាជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- អនុវត្តវិធានការផ្តល់រង្វាន់ និងទណ្ឌកម្ម ចំពោះសិស្សល្អត្រូវលើកទឹកចិត្ត ចំពោះសិស្សដែលប្រព្រឹត្តល្មើសទៅនឹងបទបញ្ជាផ្ទៃក្នុង ត្រូវណែនាំ ចាត់វិធានការរដ្ឋបាល និងអាចដាក់ទណ្ឌកម្មឈានទៅដល់ការលុបឈ្មោះចេញពីសាលារៀន អាស្រ័យទៅលើកំហុស ឬអំពើល្មើសដែលបានប្រព្រឹត្ត
- អនុវត្តវិធានការតាមផ្លូវច្បាប់ ករណីក្មេងទំនើង។

## ២. គណៈកម្មការគ្រប់គ្រងសាលារៀន

- ជំរុញការអនុវត្តសៀវភៅណែនាំប្រតិបត្តិស្តីពី កិច្ចការពារកុមារនៅក្នុងសាលារៀន
- ចូលរួមទប់ស្កាត់បាតុភាពអវិជ្ជមាននានា
- តាមដានការអនុវត្តនូវវិធីសាស្ត្រនៃការដាក់វិន័យតាមបែបវិជ្ជមាន និងការងាររបស់ក្រុមប្រឹក្សាយុវជនកម្ពុជា និងក្រុមប្រឹក្សាកុមារកម្ពុជា
- ចូលរួមក្នុងដំណើរការសម្របសម្រួល និងសេវាគាំទ្រដល់សិស្ស នៅពេលមានករណីអំពើហិង្សាណាមួយកើតឡើង
- សហការជាមួយមាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ រៀបចំកិច្ចប្រជុំ ឬកម្មវិធីផ្សេងៗ ដើម្បីពង្រឹងការចូលរួមរបស់មាតាបិតា ក្នុងការអប់រំចរិយាសម្បទា។

## ៣. គ្រូទទួលបន្ទុកថ្នាក់ និងគ្រូបង្រៀន

- បង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន
- បង្កើតប្រព័ន្ធទំនាក់ទំនងជាមួយមាតាបិតា ដើម្បីផ្តល់ព័ត៌មានអំពី អវត្តមាន ឬហេតុការណ៍ផ្សេងៗ ដែលកើតឡើងចំពោះសិស្សទៅដល់មាតាបិតា ឬអ្នកអាណាព្យាបាល
- បញ្ជ្រាបការអប់រំសីលធម៌ និងសុជីវធម៌ដល់សិស្សក្នុងម៉ោងបង្រៀន និងអង្កេតមើលសកម្មភាពរបស់សិស្សជាប់ជាប្រចាំ ដោយផ្តល់មតិកែលម្អនៅពេលដែលឃើញមានកំហុសឆ្គង ឬភាពមិនប្រក្រតីណាមួយ
- សហការផ្តល់ព័ត៌មាន និងរកដំណោះស្រាយឱ្យបានទាន់ពេលវេលា ដើម្បីបង្ការនិងទប់ស្កាត់អ្នកសិក្សាកុំឱ្យប្រព្រឹត្តសកម្មភាពមិនប្រក្រតី
- ផ្តល់មូលវិចារណ៍អំពីចរិយាសម្បទារបស់សិស្សនៅក្នុងសៀវភៅតាមដានការសិក្សា និងសៀវភៅសិក្ខាគារិក។

## ៤. មាតាបិតា ឬអ្នកអាណាព្យាបាល និងសហគមន៍

- សហការ ចូលរួម និងផ្តល់ការគាំទ្រកម្មវិធីអប់រំ ការប្រឹក្សា សកម្មភាពសង្គម សកម្មភាពលើកកម្ពស់វប្បធម៌សន្តិភាព កម្មវិធីសំដែងធម៌ទេសនា បឋកថាអំពីសីលធម៌ឬសុជីវធម៌ ដែលរៀបចំដោយគណៈគ្រប់គ្រងសាលារៀន

- ពិនិត្យមើលសកម្មភាពរស់នៅរបស់កូនចៅ ជាពិសេសការអប់រំឱ្យចៀសឆ្ងាយពីការប្រើប្រាស់គ្រឿងញៀន ការជក់បារី និងការលេងល្បែងស៊ីសងគ្រប់ប្រភេទ
- តាមដានការសិក្សា ដោយត្រូវសួរនាំ និងណែនាំកូនចៅនៅពេលមានកំហុស
- សហការជាមួយសាលារៀន ដោយចូលរួមកិច្ចប្រជុំ និងសហការជាមួយគ្រូបង្រៀន ដើម្បីដោះស្រាយបញ្ហា និងលើកទឹកចិត្តកូនចៅ។

**៥. សិស្ស**

- គោរពតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សា និងអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ និងគោរពសិទ្ធិអ្នកដទៃ
- រក្សាភាពថ្លៃថ្នូរ សីលធម៌ និងសុជីវធម៌
- អនុវត្តតាមកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា ដែលគ្រឹះស្ថានសិក្សាបានកំណត់ ដូចជាចូលរួមស្តាប់កម្មវិធីសំដែងធម៌ទេសនា ឬបកថាអំពីសីលធម៌ ឬសុជីវធម៌
- មិនត្រូវប្រើប្រាស់ទូរស័ព្ទដៃក្នុងថ្នាក់រៀន ទោះក្នុងម៉ោងរៀន ឬម៉ោងចេញលេង លើកលែងតែមានការអនុញ្ញាត
- មិនត្រូវលេងល្បែងស៊ីសង ឬល្បែងភ្នាល់គ្រប់ប្រភេទនៅក្នុងគ្រឹះស្ថានសិក្សា
- មិនត្រូវជក់បារីគ្រប់ប្រភេទនៅក្នុងគ្រឹះស្ថានសិក្សា។

**៦. មន្ទីរអប់រំ យុវជន និងកីឡា**

- ត្រូវផ្សព្វផ្សាយ និងពង្រឹងការដឹកនាំ និងគ្រប់គ្រងគ្រឹះស្ថានសិក្សាឱ្យមានប្រសិទ្ធភាព ជាពិសេសការអនុវត្តបទបញ្ជាផ្ទៃក្នុងគ្រឹះស្ថានសិក្សា និងគោលការណ៍ពាក់ព័ន្ធឱ្យបានទូលំទូលាយ
- សហការ សម្របសម្រួល និងជំរុញការអនុវត្តសកម្មភាពក្រៅម៉ោងសិក្សា ដូចជា កម្មវិធីអប់រំចិត្ត កម្មវិធីប្រឹក្សាយោបល់ បាឋកថាអំពីសីលធម៌ ឬ សុជីវធម៌ប្រចាំសប្តាហ៍ កម្មវិធីអប់រំសីលធម៌ ការងារស្ម័គ្រចិត្ត កីឡា ក្លឹបសិក្សា សកម្មភាពបណ្ណាល័យ និងការសិក្សាស្រាវជ្រាវជាក្រុម
- សម្របសម្រួល និងដោះស្រាយបញ្ហាឬបាតុភាពនានា ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់
- រាយការណ៍រាល់សកម្មភាពមិនប្រក្រតី និងបាតុភាពនានា ដល់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា។

**៧. រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

- ត្រូវផ្សព្វផ្សាយ និងពង្រឹងការដឹកនាំ គ្រប់គ្រងគ្រឹះស្ថានសិក្សាឱ្យមានប្រសិទ្ធភាព ជាពិសេសការអនុវត្តបទបញ្ជាផ្ទៃក្នុងគ្រឹះស្ថានសិក្សា និងគោលការណ៍ពាក់ព័ន្ធឱ្យបានទូលំទូលាយ
- សហការ សម្របសម្រួល និងជំរុញការអនុវត្តសកម្មភាពក្រៅម៉ោងសិក្សា ដូចជា កម្មវិធីអប់រំចិត្ត កម្មវិធីប្រឹក្សាយោបល់ បាឋកថាអំពីសីលធម៌ ឬ សុជីវធម៌ប្រចាំសប្តាហ៍ កម្មវិធីអប់រំសីលធម៌ ការងារស្ម័គ្រចិត្ត កីឡា ក្លឹបសិក្សា សកម្មភាពបណ្ណាល័យ និងការសិក្សាស្រាវជ្រាវជាក្រុម

- សម្របសម្រួល និងដោះស្រាយបញ្ហាឬបាតុភាពនានា ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់
- រាយការណ៍រាល់សកម្មភាពមិនប្រក្រតី និងបាតុភាពនានា ដល់មន្ទីរអប់រំ យុវជន និងកីឡា ឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវជំរុញការផ្សព្វផ្សាយ និងសហការអនុវត្តឱ្យបានទូលំទូលាយ។ នាយកនាយិកានៃគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ ប្រធានអង្គភាពពាក់ព័ន្ធ បុគ្គលិកអប់រំ និងសិស្សានុសិស្សត្រូវអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព។

ថ្ងៃចន្ទ ១៣រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ "ដើម្បីជូនជ្រាប"
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត
- គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
  "ដើម្បីសហការអនុវត្ត"
- គ្រប់គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ នា. នីតិកម្ម